**ការខ្វីខ្វា** (recklelessness)

ពាក្យនេះ មានអត្ថន័យមិនច្បាស់លាស់ទេ។ ក្នុងន័យទូទៅ មានន័យថា មិនខ្វល់នូវហានិភ័យ និងលទ្ធផលនៃទង្វើរបស់។ ច្បាប់ប្រទេសអង់គ្លេស ទទួលស្គាល់នូវការខ្វីខ្វា ជាពីរប្រភេទ តាមយុត្តិសាស្ត្រ Cunningham និង Lawrence ដែលទីមួយ ទាមទារនូវការដឹងជាក់ស្តែងនូវហានិភ័យ ហើយទី២ វាមានភាពគ្រប់គ្រាន់ហើយចំពោះការខកខានមិនបានពិចារណាលើហានិភ័យ។

បញ្ហាជាបឋម គេទាមទារនូវកម្រិតនៃហានិភ័យ និង ភាពមិនអាចយុត្តិកម្មបាន ([justification](justification))។ ហានិភ័យ ត្រូវតែធំ ឬធ្ងន់ធ្ងរ (substantial) ទោះបីលទ្ធភាពកើតមានទាបជាង៥0% ក្តី។ ហានិភ័យនៃសេចក្តីស្លាប់ ត្រូវតែជាហានិភ័យធំ។ លទ្ធភាពកើតខ្ពស់នៃហានិភ័យតូច មិននាំឲ្យជាហានិភ័យធំដំទេ។ សម្រាប់ប្រទេសស៊ីវិលឡ លទ្ធផលនៃទង្វើ គឺគ្រាន់តែលទ្ធភាពដែលអាចកើតមាន (possible)។ ហានិភ័យ ស្តែងចេញពីការងាកចេញឆ្ងាយពីស្តង់ដារនៃទង្វើ នៃបុគ្គលហ្មត់ចត់ គោរពច្បាប់ ស្ថិតនៅក្នុងស្ថានភាពដូចគ្នា (gross deviation from standards of conduct of a prudent undergoing the same situation)។

បញ្ហាទី២ គឺស្ថានភាពផ្លូវចិត្តរបស់ជនល្មើស ([state of mind](state of mind))។ នោះគឺជាការណ៍ដែលដឹងថា មានហានិភ័យ តែគាត់មិនបានគិតអំពីហានិភ័យ។ ក៏ប៉ុន្តែ ករណីខ្លះ ជនល្មើស បានគិតខុស។

យុត្តិសាស្ត្រ Cuuningham Recklessness ទាមទារដឹងនូវផលវិបាកខុសច្បាប់ នៃទង្វើរបស់អ្នកប្រព្រឹត្ត។ នេះក្នុងន័យថា គាត់ដឹងហានិភ័យ ហានិភ័យខុសច្បាប់ តែនៅតែធ្វើសកម្មភាព។

ហានិភ័យក្នុងយុត្តិសាស្ត្រ Lawrence តម្រូវនូវធាតុផ្សំចំនួនពីរ៖១. លទ្ធភាពដែល ទង្វើរបស់ជនល្មើស បង្កឲ្យមានផលវិបាកហានិភ័យធ្ងន់ធ្ងរ (objective approach) និងទី២. ហានិភ័យនៃផលវិបាកនោះ មិនតូចតាច (inadvertent recklessnes) ដែលអាចកើតមាន ដោយសារទង្វើធ្វេសប្រហែស([negligence](negligence))។ ការខ្វីខ្វាតិចតួច (inadvertent recklessness) ទាញពី Lawrence មាន ប្រភេទនៃហានិភ័យ និង ជំហរ (attitude) ចំពោះហានិភ័យនោះ។

**ខ្លឹមសារបន្ថែម៖** ជនម្នាក់បានដឹងថា បន្ទប់មួយពោរពេញដោយមនុស្ស បើបាញ់ចូលទៅខាងក្នុង ចង់មិនចង់នឹងមានអ្នកស្លាប់ គាត់មិនខ្វល់គាត់ក៏បានបាញ់។ ហានិភ័យគឺស្លាប់ តែគាត់មិនគិតពីការស្លាប់។ នេះ ជាការខ្វីខ្វា ឬមិនខ្វល់។ ក្នុងករណីនេះ ប្រសិនថា ការបាញ់កាំភ្លើងមានយុត្តិកម្ម (បង្ក្រាបចោរ) ក៏ប៉ុន្តែ ធ្វេសប្រហែសមិនបានគោរពវិធាន (standard of care) បណ្តាលឲ្យកុមារ ដែលស្ថិតនៅក្នុងចំណោមពួកចោរនៅក្នុងបន្ទប់ទាំងនោះស្លាប់ វានឹងជាទង្វើធ្វេសប្រហែសបណ្តាលឲ្យកុមារស្លាប់។ ករណីទី១

តាមប្រទេសខ្លះ តម្លើង recklessness ទៅជាចេតនាផ្ទាល់ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 479-482)។